

# តើអ្នកកំពុងចាំអ្វី?

Naafi Nur Rohma



នីណា កំពុងលេងជាមួយឆ្មារបស់នាងឈ្មោះ បូបូ។







នៅរានហាលមុខផ្ទះ នីណា សម្លឹងមើលទៅបងប្រុសនាងគឺ វ៉ាន់ឌី។ គេហាក់ដូចជាកំពុងរង់ចាំអ្វីមួយ។
នីណា ក៏សួរថា ”តើបងកំពុងធ្វើអ្វី?”
វ៉ាន់ឌី គ្រាន់តែញញឹមដាក់នាងប៉ុណ្ណោះ។



នីណា ចាប់ផ្ដើមងឿងឆ្ងល់ ហើយសួរបន្តទៀតថា ”តើបងកំពុងរង់ចាំអ្វី? ប្រាប់ខ្ញុំផងបានទេ?”
”វាជារឿងសម្ងាត់” វ៉ាន់ឌី ចំអន់នាងលេង ដោយញញឹម។



អូ! នីណា ដឹងហើយ។ វ៉ាន់ឌី គ្មានទៅណាឆ្ងាយពីចំណីនោះទេ។

"ខ្ញុំដឹងហើយ! បងច្បាស់ជាកំពុងរង់ចាំប្រហិតហើយ! នោះអ្នកលក់ប្រហិត!"

វ៉ាន់ឌី ហាក់សប្បាយចិត្តពេលឃើញអ្នកលក់ប្រហិត ប៉ុន្តែ...



”មិនមែនប្រហិតទេ!” វ៉ាន់ឌី ឆ្លើយ។ នីណា ស្ទើរតែមិនជឿ។ នាងបានត្រឹមសម្លឹងមើលអ្នកលក់ដើរកាត់ផុតទៅ។



”នោះ! បងច្បាស់ជាកំពុងរង់ចាំនំអាកោហើយ តើត្រូវទេ?” វ៉ាន់ឌី គ្រាន់តែញញឹមបន្តិចដាក់អ្នកលក់នំអាកោនោះ។ ប៉ុន្តែការពិត...



"អត់ទេ! អ្នកណាថាបងកំពុងអង្គុយចាំអ្នកលក់នំអាកោ?" វ៉ាន់ឌី គ្រវីក្បាល ហើយនិយាយ។

នីណា ភ្ញាក់ផ្អើលយ៉ាងខ្លាំង។ វ៉ាន់ឌី មិនបានហៅអ្នកលក់នំអាកោឱ្យឈប់ដូចរាល់ដងនោះឡើយ។



"ខ្ញុំដឹងហើយ! បងច្បាស់ជារង់ចាំស៊ុបគោហ៊ូនោះជាមិនខាន!"
នីណា ទាយម្ដងទៀត។





វ៉ាន់ឌី សើចតិចៗ រួចតបថា "ទេ! បងមិនមែនរង់ចាំស៊ុបតៅហ៊ូ នោះទេ។"

ដូចនេះ តើ វ៉ាន់ឌី កំពុងតែរង់ចាំអ្វី? នីណា មិនជឿសោះថា វ៉ាន់ឌី បែរជាប្រកែកមិនទិញស៊ុបតៅហ៊ូទៅវិញ។



នីណា កាន់តែចង់ដឹង។ តើ វ៉ាន់ឌី កំពុងរង់ចាំអ្វីឱ្យប្រាកដ?



"បាយឆា? ប្រហិតតៅហ៊ូ?" នីណា ព្យាយាមទាយ ឯ វ៉ាន់ឌី គ្រវីក្បាលរហូត។



ភ្លាមនោះ វ៉ាន់ឌី ក៏ស្ទុះរត់ទៅរកឪពុករបស់ខ្លួនដែលកំពុងតែដើរ
សំដៅមកផ្ទះ។
អូ! នោះគឺជាបាយលាភជ័យ នៅក្នុងប្រអប់ដែលយកមកពី
ពិធីបុណ្យទេតើ! វ៉ាន់ឌី កំពុងតែរង់ចាំបាយនេះសោះ។



”កុំញ៉ាំអស់តែឯង!” នីណា ស្រែក។



ប្រអប់បាយមានក្លិនឈ្ងុយ។
នីណា អាចដឹងថាក្នុងប្រអប់បាយមានអ្វីខ្លះ។ វាក៏ជាម្ហូបដែល
នាងចូលចិត្តផងដែរ ប៉ុន្តែ...



វ៉ាន់ឌី គិតតែពីញ៉ាំ។ តើ វ៉ាន់ឌី ទុកខ្លះឱ្យ នីណា ញ៉ាំទេ?



”កុំយំ! នេះនែ បងទុកពងទាស្ងោរដែលឯងចូលចិត្ត។” វ៉ាន់ឌី ចង្អុលទៅប្រអប់បាយ។
នីណា ក៏ឈប់យំ។





តើប្អូនៗក៏ចង់អង្គុយចាំញ៉ាំបាយលាភជ័យដូច វ៉ាន់ឌី ដែរ
មែនទេ?

The Asia Foundation
Improving Lives, Expanding Opportunities

litara
Foundation

រក្សាសិទ្ធិដោយ មូលនិធិអាស៊ី ឆ្នាំ២០១៩
សៀវភៅនេះត្រូវបានផលិតឡើងតាមរយៈសិក្ខាសាលាអំពីការផលិតសៀវភៅជាភាសាក្នុងស្រុកក្រោមកិច្ចសហការរវាងមូលនិធិ លីតារ៉ា និងមូលនិធិអាស៊ី។ កម្មវិធី និងការអភិវឌ្ឍជំនាញ រួមទាំងការតាក់តែង និងរចនាសៀវភៅនេះ គឺត្រូវបានរៀបចំដោយមូលនិធិលីតារ៉ា។

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org


**Original Story**

*Ngenteni Apa, Mas? (What are You Waiting For?)*, Illustrator: Naafi Nur Rohma. Published by The Asia Foundation - Let's Read, © The Asia Foundation - Let's Read. Released under CC BY-NC 4.0.



This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC BY-NC 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by-nc/4.0/



Contributing translators: sorpheapeou@gmail.com, honchakriya2000@gmail.com, unalis.student@puthisastra.edu.kh, Sivgecht@gmail.com, and sreyrothkun48@gmail.com